សេចក្តីថ្លែងការណ៍រួម

# សង្គមស៊ីវិល សូមថ្កោលទោសចំពោះអំពើហិង្សានៅលើអ្នកតំណាងរាស្ត្រកម្ពុជា

ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

សមាគមអាដហុក ការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) សមាគមធាងត្នោត (STT) និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ (LICADHO) សូមធ្វើការថ្កោលទោសចំពោះអំពើហិង្សានៅមុខវិមានរដ្ឋសភាជាតិ និងនៅមុខរបងគេហដ្ឋានរបស់មេដឹកនាំគណបក្សជំទាស់ កាលពីរសៀលម្សិលមិញនេះ ដែលបណ្តាលឲ្យអ្នកតំណាងរាស្ត្រមកពីគណបក្សជំទាស់ពីររូប រងរបួសយ៉ាងដំណំ និងអំពាវនាវឲ្យមានការស៊ើបអង្កេតដោយឯករាជ្យ និងមានតម្លាភាពទៅលើការបង្កហិង្សានោះ។ យើងខ្ញុំ ក៏មានការព្រួយបារម្ភផងដែរទៅលើកង្វះខាតវិធានការរបស់នគរបាលក្នុងការគ្រប់គ្រងការប្រមូលផ្តុំនៅមុខគេហដ្ឋានឯកឧត្តម កឹម សុខា ដែលត្រូវបានឡោមព័ទ្ធដោយមនុស្សជាច្រើនរយនាក់កាលពីរសៀលម្សិលមិញ ដោយក្នុងចំណោមនោះមានមនុស្សមួយចំនួនបានគប់ដុំថ្មចូលក្នុងបរិវេណគេហដ្ឋានរបស់លោក ហើយមានមនុស្សមួយចំនួនទៀត ត្រូវបានគេឮថាបានអំពាវនាវឲ្យមានអំពើហិង្សាបន្តទៀត។

អ្នកតវ៉ាដែលត្រូវបានរៀបចំឡើងយ៉ាងល្អប្រមាណជាង ២.៥០០ នាក់ (ភាគច្រើននៃអ្នកទាំងនោះបានបង់ក្រមាក្រហម និងក្រណាត់ក្រហមបិទភ្ជាប់នឹងអាវរបស់អ្នកទាំងនោះ) បានប្រមូលផ្តុំគ្នានៅមុខវិមានរដ្ឋសភាជាតិកាលពីព្រឹកម្សិលមិញ ដោយអំពាវនាវសុំឲ្យអនុប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ចុះចេញពីតំណែងអនុប្រធានទីមួយរដ្ឋសភា ជាតំណែងដែលលោកបានកាន់ចាប់តាំងពីខែសីហា ឆ្នាំ២០១៤ បន្ទាប់ពីមានកិច្ចព្រមព្រៀងនយោបាយរវាងគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ដើម្បីបិទបញ្ចប់ការជាប់គាំងនយោបាយអស់រយៈពេលជិតមួយឆ្នាំមក។

អ្នកឃ្លាំមើលចំណាំបានកងសន្តិសុខនិងមន្ត្រីនគរបាលជាច្រើននាក់ បានស្លៀកសំលៀកបំពាក់ស៊ីវិលនៅក្នុងចំណោមក្រុមបាតុករទាំងនោះ ដែលនៅក្នុងក្រុមនោះក៏មានសមាជិកក្រុមយុវជនគណបក្សប្រជាជនកម្ពុជាផងដែរ។ នាព្រឹកមិញនេះ នគរបាលសម្រាប់គ្រប់គ្រងការតវ៉ានោះ គឺមានត្រឹមតែនគរបាលចរាចរណ៍មួយចំនួនតូចប៉ុណ្ណោះ ដើម្បីសម្រួលចរាចរណ៍ ដែលនេះមានភាពផ្ទុយគ្នាស្រឡះពីការប្រើប្រាស់កងកម្លាំងយ៉ាងច្រើនសន្ធឹកសន្ធាប់របស់នគរបាលក្នុងការអនុវត្តចំពោះអ្នកតវ៉ាឯទៀតនៅក្នុងរាជធានីភ្នំពេញនាពេលកន្លងទៅ។

នៅម៉ោងប្រមាណ ១២ និង៣០នាទី ថ្ងៃត្រង់ អ្នកតវ៉ាជាច្រើនក្រុមមានពាក់ក្រមាក្រហម បានទាញអ្នកតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិពីររូប (ឯកឧត្តម គង់ សភា និងឯកឧត្តម ញ៉យ ចំរើន)

ចេញពីរថយន្តរបស់អ្នកទាំងពីរ នៅពេលពួកលោកចាកចេញពីវិមានរដ្ឋសភា ហើយវាយដំទៅលើអ្នកទាំងពីរយ៉ាងដំណំ។ វីដេអូខ្លីអំពីការវាយប្រហារនេះបានបង្ហាញថា អ្នកទាំងពីរបានដួលលើដី នៅក្រៅវិមានរដ្ឋសភាជាតិ ដោយមានរបួសយ៉ាងច្បាស់ដែលបណ្ដាលមកពីការវាយដំ និងទាត់ធាក់ចំមុខរបស់អ្នកទាំងពីរ។ អ្នកតវ៉ាមួយចំនួន បានបំបែកកញ្ចក់ឡានមួយផ្ទាំងរបស់អ្នកតំណាងរាស្ដ្រម្នាក់ក្នុងចំណោមអ្នកតំណាងរាស្ដ្រទាំងពីរ។ របួសអ្នកទាំងពីរតម្រូវឲ្យមានការព្យាបាល។

នៅពេលដែលការតវ៉ានៅមុខវិមានរដ្ឋសភាជាតិជិតបញ្ចប់ អ្នកតវ៉ាមួយក្រុមតូចដែលមានសមាជិកប្រមាណ ៣០០នាក់ មានពាក់ក្រមាក្រហម បានធ្វើដំណើរទៅប្រមូលផ្ដុំគ្នានៅមុខគេហដ្ឋានរបស់ឯកឧត្ដម កឹម សុខា នៅទួលគោក។ ក្រុមមនុស្សមានភាពគ្រេវគ្រោធមួយក្រុម ដែលក្នុងនោះមានមនុស្សមួយចំនួនកាន់ជំពាមកៅស៊ូនិងដុំថ្មជាច្រើន បានបន្តអំពាវនាវឲ្យឯកឧត្ដម កឹម សុខា ចុះចេញពីតំណែង និងបានគប់ដបទឹកសុទ្ធ និងដុំថ្មជាច្រើនចូលទៅក្នុងបរិវេណគេហដ្ឋានរបស់លោក។ ចំពោះលើកនេះដែរ មិនមានកងសន្តិសុខឯកសណ្ឋានមានវត្តមាននោះទេ គឺមានតែនគរបាលចរាចរណ៍ពីរនាក់ដើម្បីគ្រប់គ្រងក្រុមបាតុករប៉ុណ្ណោះ ដែលធ្វើឲ្យសកម្មភាពរបស់ក្រុមមនុស្សទាំងនោះត្រូវបានធ្វើឡើងដោយមិនមានការរំខាន អស់ជាច្រើនម៉ោង។

លោក អំ សំអាត អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ បានមានប្រសាសន៍ថា៖ "នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ យើងបានឃើញថាមានការតវ៉ាជាច្រើនរាប់មិនអស់ដែលត្រូវបានបំបែកយ៉ាងហិង្សានៅក្នុងរាជធានីភ្នំពេញ ដោយប្រើប្រាស់កម្លាំងកងសន្តិសុខយ៉ាងច្រើនហួសហេតុ (ប៉ុន្តែក្នុងព្រឹត្តិការណ៍ដែលតំណាងរាស្ដ្រទាំងពីររងរបួសម្សិលមិញនេះ មិនមានវត្តមានកងសន្តិសុខមកបំបែកបាតុករដូចសព្វដងនោះទេ)"។ លោកបានបន្តទៀតថា៖ "យើងសង្ឃឹមថាអ្នកដែលទទួលខុសត្រូវលើអំពើហិង្សានាម្សិលមិញនេះ នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ហើយទទួលទោសតាមច្បាប់ជាធរមាន។"

នៅពេលដែលមន្ត្រីរាជរដ្ឋាភិបាលមួយចំនួនបានអះអាងថា គណបក្សប្រជាជនមិនបាននៅពីក្រោយការតវ៉ាកាលពីព្រឹកម្សិលមិញនោះ សារព័ត៌មានដែលគាំទ្រគណបក្សប្រជាជន បានផ្សព្វផ្សាយញត្តិទាមទាររបស់គណបក្សប្រជាជនកម្ពុជាសាខាខេត្ត ឧត្ដរមានជ័យ កាលពីរសៀលម្សិលមិញ ដោយទាមទារដូចគ្នានឹងអ្នកតវ៉ាផងដែរ។ ញត្តិមួយផ្សេងទៀត ដែលត្រូវបានផ្សព្វផ្សាយកាលពីម្សិលមិញដែលចុះហត្ថលេខាដោយមេបញ្ជាការរងនៃកងយុទ្ធពលខេមរភូមិន្ទ លោក គន់ គីម ក៏ដូចជាមេបញ្ជាការយោធាជាន់ខ្ពស់ ស្រី ឌឹក ដែលអ្នកទាំងពីរជាសមាជិកនៅក្នុងគណកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សប្រជាជនកម្ពុជា ក៏បានអំពាវនាវឲ្យឯកឧត្ដម កឹម សុខា ចុះចេញពីតំណែងផងដែរ។

អំពើហិង្សាកាលពីម្សិលមិញ បានកើតឡើងបន្ទាប់ពីមានសុន្ទរកថាជាច្រើនដែលត្រូវបានធ្វើឡើងដោយមេដឹកនាំគណបក្សកាន់អំណាច និងគណបក្សជំទាស់។ បន្ទាប់ពីមេដឹកនាំគណបក្សជំទាស់

ឯកឧត្តម សម រង្ស៊ី បាននិយាយថាជាសិទ្ធិរបស់ពលរដ្ឋកម្ពុជាក្នុងការតវ៉ានៅក្នុងទីក្រុងប៉ារីស នៅអំឡុងពេលដែលសម្តេចនាយករដ្ឋមន្ត្រី ធ្វើទស្សនកិច្ចផ្លូវការក្នុងប្រទេសបារាំង រីឯសម្តេចនាយករដ្ឋមន្ត្រី ក៏បានឆ្លើយតបថាក៏នឹងមានការតវ៉ាមួយចំនួននៅក្នុងរាជធានីភ្នំពេញផងដែរហើយនិងឯកឧត្តម កឹម សុខា អាចនឹងត្រូវបាត់បង់តំណែងជាអនុប្រធានសភាផងដែរ។ កាលពីពីរថ្ងៃមុន ឯកឧត្តម កឹម សុខា បានថ្លែងសុន្ទរកថានៅខេត្តព្រះសីហនុថា គណបក្សសង្គ្រោះជាតិ អាចនឹងឈ្នះក្នុងការបោះឆ្នោតអណត្តិក្រោយឆ្នាំ ២០១៨ ប្រសិនបើគ្រប់គ្នាដែលមានសិទ្ធិបោះឆ្នោត មានចុះឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*


- លោក នី ចរិយា, ប្រធានផ្នែកសិទ្ធិមនុស្ស និងជំនួយផ្នែកច្បាប់ នៃសមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, លេខទូរស័ព្ទ ០១១ ២៧៤ ៩៥៩,<br>អ៊ីមែល៖ adhoc.chakrya@gmail.com
- អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លេខទូរស័ព្ទ ០១១ ៩៤៣ ២១៣, អ៊ីមែល៖ chaksopheap@cchrcambodia.org
- លោក អំ សំអាត អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ, លេខទូរស័ព្ទ ០១២ ៣២៧ ៧៧០, អ៊ីមែល៖ mon1@licadho-cambodia.org